ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៩......សហវ.......

ថ្ងៃ ពុធ ១០រោច ខែស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២១

# សារាចរណែនាំ
## ស្តីពី
## ការប្រើប្រាស់ភាសា និង រូបិយប័ណ្ណ
## ក្នុងបញ្ជីគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងក្នុងគោលបំណងសម្រួលដល់ការធ្វើធុរកិច្ចរបស់ធុរជនដោយអាចរក្សាបានគុណតម្លៃនៃភាសាខ្មែរ និងប្រាក់រៀលព្រមទាំងអាចធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំ ដូចខាងក្រោម÷

១-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចប្រើភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យ ក្នុងករណីដែលសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញពុំទាន់អាចរកបានប្រព័ន្ធកុំព្យូទ័រទាំងនោះ ដែលអាចប្រើភាសាខ្មែរបានតាមតម្រូវការប្រតិបត្តិការរបស់ខ្លួន។ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញពុំបានតម្រូវឱ្យស្នើសុំលើការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធកុំព្យូទ័រទាំងនោះឡើយ ប៉ុន្តែសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវជូនដំណឹងជាលាយល័ក្ខអក្សរមក**និយ័តករគណនេយ្យនិងសវនកម្ម** ដោយបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះ និងប្រភពនៃប្រព័ន្ធកុំព្យូទ័រដែលកំពុងប្រើនោះ។

២-ឯកសារគណនេយ្យផ្ទៃក្នុងដែលគាំទ្រដល់កិច្ចបញ្ជិកាគណនេយ្យ ត្រូវជាភាសាខ្មែរ។ ឯកសារទាំងនេះ អាចត្រូវ បានអនុញ្ញាតឱ្យប្រើភាសាអង់គ្លេសអមជាមួយភាសាខ្មែរបាន។ ចំពោះឯកសារគណនេយ្យដែលបង្កើតចេញពីប្រព័ន្ធកុំព្យូទ័រដែលមិនអាចប្រើភាសាខ្មែរបានដូចមានចែងក្នុងចំណុចទី ១ខាងលើ និងឯកសារគណនេយ្យដែលត្រូវបានរៀបចំ និងផ្តល់ដោយ ដៃគូធុរកិច្ចបរទេស ឬដោយអង្គការដៃគូ ឬម្ចាស់ជំនួយបរទេស ឬសម្រាប់ធុរកិច្ចជាមួយដៃគូធុរកិច្ចបរទេស ឯកសារទាំងនោះអាចជាភាសាអង់គ្លេសបាន។ ក្នុងករណីឯកសារគាំទ្រការធ្វើធុរកិច្ច ឬប្រតិបត្តិការក្រៅពីភាសាខ្មែរ និងភាសាអង់គ្លេស សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវទទួលខុសត្រូវបកប្រែឯកសារទាំងនោះទៅជាភាសាខ្មែរ ឬភាសាអង់គ្លេស ដោយមានប្រថាប់ត្រារបស់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញផ្ទាល់។

<u>ឧទាហរណ៍</u>÷ កិច្ចសន្យាទិញ-លក់ដែលត្រូវបានរៀបចំជាភាសាបរទេស (ក្រៅពីភាសាអង់គ្លេស) ដូចនេះ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវបកប្រែកិច្ចសន្យានោះជាភាសាខ្មែរ ឬភាសាអង់គ្លេស ដោយមាន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ហត្ថលេខាទទួលស្គាល់លើខ្លឹមសារនៃអត្ថបទបកប្រែរបស់ម្ចាស់សហគ្រាស ឬអ្នកមានសិទ្ធិ និងមានប្រថាប់ត្រារបស់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញផ្ទាល់។

៣-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចជ្រើសរើសរូបិយប័ណ្ណមុខងារជាប្រាក់រៀល ឬរូបិយប័ណ្ណបរទេសតាមគោលនយោបាយគណនេយ្យរបស់ខ្លួនដោយអនុលោមតាមស្តង់ដាគណនេយ្យជាធរមាន សម្រាប់កត់ត្រាប្រតិបត្តិការគណនេយ្យប្រចាំថ្ងៃ។

៤-សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជាភាសាខ្មែរ និងបង្ហាញជាប្រាក់រៀល ឬបង្ហាញជាប្រាក់រៀលផងនិងរូបិយប័ណ្ណបរទេសផង។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជាប្រាក់រៀល សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវអនុវត្តតាមការណែនាំក្នុងស្តង់ដាគណនេយ្យជាធរមាន ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការដែលបានបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា ហើយត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនោះ មកនិយ័តករគណនេយ្យនិងសវនកម្ម តាមសេចក្តីណែនាំរបស់ និយ័តករគណនេយ្យនិងសវនកម្មដើម្បីជាកម្មវត្ថុនៃការរក្សាទុក និងការត្រួតពិនិត្យលើកម្រិតអនុលោមភាព ស្របតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

៥-ចំពោះសហគ្រាសដែលធ្វើប្រតិបត្តិការប្រេងកាតនៅក្នុងដែនអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមប្រកាស ៥៣៦ សហវ.ប្រក ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការណែនាំអនុវត្តបទប្បញ្ញត្តិស្តីពី ពន្ធលើប្រតិបត្តិការប្រេងកាត។

៦-ក្នុងអំឡុងពេលនៃការអនុវត្តសារាចរនេះ និយ័តករគណនេយ្យនិងសវនកម្ម ត្រូវពិនិត្យ តាមដាន និងវាយតម្លៃលើលទ្ធភាពនៃការកាន់បញ្ជីគណនេយ្យជាភាសាខ្មែរ និងប្រាក់រៀល ។

៧- និយ័តករគណនេយ្យនិងសវនកម្ម អាចស្នើឡើងនូវវិធានចាំបាច់នានាបន្ថែមសម្រាប់ការអនុវត្តសារាចរនេះ។

ទទួលបានសារាចរណែនាំនេះ និយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកដ្ឋានពន្ធដារ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ស្ថាប័នពាក់ព័ន្ធ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវសហការអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ តទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល ÷</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ